សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព
របស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ
សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ
២០ មិនា ២០១៥

- **សូមគោរព លោកវេជ្ជបណ្ឌិត ហែម សាវត ប្រធានមន្ទីរសុខាភិបាលខេត្តតាកែវ**
- **សូមគោរព លោកវេជ្ជបណ្ឌិត ឈ្មាង សុវុត្ថា ប្រធានមន្ទីរសុខាភិបាលខេត្តក្រចេះ**
- **សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីប្រារព្ធពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិចំនួនពីររួមមាន "គម្រោងសាងសង់អគារជម្ងឺទូទៅមួយខ្នងនៅមន្ទីរពេទ្យរងរមេញ នៃមន្ទីរពេទ្យបង្អែកគិរីវង់ ខេត្តតាកែវ" និង"គម្រោងសាងសង់មណ្ឌលសុខភាពកំពង់ចាម ក្នុងស្រុកសំបូរ ខេត្តក្រចេះ។

គម្រោងទាំងពីរ ដែលយើងតែបានចុះហត្ថលេខានៅថ្ងៃនេះ មានគោលដៅដើម្បីផ្តល់សេវាសុខភាពប្រកបដោយគុណភាពជូនដល់ប្រជាពលរដ្ឋនៅមូលដ្ឋាននៃគម្រោងនិមួយៗ។ យើងទទួលស្គាល់ថា វិស័យសុខាភិបាល គឺជាវិស័យអាទិភាពសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា ហើយយើងជឿជាក់យ៉ាងមុតមាំថា ការកែលម្អវិស័យសុខាភិបាលនេះ គឺជាគន្លឹះដ៏សំខាន់សម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា ក៏ដូចជាការពង្រឹងនូវសុខមាលភាពសម្រាប់ប្រជាជនកម្ពុជាផងដែរ។ ខ្ញុំសង្ឃឹមថា ការគាំទ្ររបស់ជប៉ុន នឹងរួមចំណែកយ៉ាងធំធេងដល់គោលបំណងទាំងនេះ។

គម្រោងទីមួយ មានថវិកាសរុប ១០៣,០៨២ដុល្លារអាមេរិក គឺដើម្បីសាងសង់អគារជម្ងឺទូទៅមួយខ្នង បំពាក់ទៅដោយគ្រែសម្រាប់អ្នកជម្ងឺ នៅមន្ទីរពេទ្យរងរមេញ នៃមន្ទីរពេទ្យបង្អែកគិរីវង់ ក្នុងខេត្តតាកែវ។ យើងរំពឹងថាគម្រោងនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋនៅក្នុងតំបន់ប្រមាណជា១៨,៧០០នាក់ អោយទទួលបាននូវសេវាសុខភាពប្រកបដោយគុណភាពល្អប្រសើរ ។

គម្រោងទីពីរ មានថវិកាសរុប ៨៩,៦៦៤ ដុល្លារអាមេរិក គឺដើម្បីសាងសង់មណ្ឌលសុខភាពមួយ នៅក្នុងឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ។ គម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ ប្រជាពលរដ្ឋប្រមាណជា ១០,០០០នាក់ អោយទទួលបាននូវសេវាសុខភាពប្រកបដោយគុណភាពល្អប្រសើរ ។

រដ្ឋាភិបាលជប៉ុន បាននឹងកំពុងបន្តផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ប្រជាជនកម្ពុជា តាមរយៈការគាំ

ទ្រដល់គម្រោងជាច្រើន។ វិស័យសុខាភិបាល គឺជាវិស័យអាទិភាពរបស់ជប៉ុនក្នុងបណ្តាលវិស័យដទៃទៀត ក្នុងការផ្តល់ជំនួយដល់រាជរដ្ឋាភិបាលកម្ពុជា ហើយរដ្ឋាភិបាលជប៉ុនក៏បាននឹងកំពុងជួយដល់ប្រទេសកម្ពុជាក្នុងវិស័យនេះយ៉ាងសកម្មផងដែរ តាមរយៈការសាងសង់អគារជម្ងឺទូទៅ និងគ្លីនិក ព្រមទាំងការផ្តល់នូវការបណ្តុះបណ្តាលនានាជាច្រើន។

ខ្ញុំសង្ឃឹមថា គម្រោងទាំងនេះ នឹងត្រូវបានអនុវត្តទៅយ៉ាងរលូន ហើយនឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវ ដើម្បីអោយប្រជាជនកាន់តែច្រើន ទទួលបានអត្ថប្រយោជន៍ពីគម្រោងទាំងនេះតាមដែលអាចទៅបាន។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថាគម្រោងទាំងនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពដែលមានស្រាប់រួចមកហើយរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!**